**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងរដ្ឋប្បវេណី
លេខ២៩៥
ចុះថ្ងៃទី១៣ខែ០៦ឆ្នាំ២០១៩
សាលក្រម
លេខ...២២៩...“ង”
ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ចាម**
បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់
នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩
និងចេញសេចក្តីសម្រេចបញ្ចប់
នៅថ្ងៃទី១០ខែកញ្ញា ឆ្នាំ២០១៩
សមាសភាពចូលរួមដូចតទៅ៖

លោក **សាយសម្ផស្សសេរី** ចៅក្រមសាលាដំបូងខេត្តកំពង់ចាម
លោក **យ៉ុន ប៉ុម** ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

**១-គាគីនៃបណ្តឹង**

-ដើមចោទ **ដ** ភេទស្រី អាយុ៥៩ឆ្នាំជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅ ខេត្តកំពង់ចាម ។

-ចុងចំលើយ **ច** ភេទស្រី អាយុ៤៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅ ខេត្តកំពង់ចាម ។

**២-សាលក្រមដែលទាមទារដោយដើមចោទ**

-ប្តឹងសុំទាមទារប្រាក់ដើមចំនួន ១១៦៥០ (មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប) ដុល្លារ

-សុំទាមទារការប្រាក់តាមច្បាប់។

-សុំទាមទារជម្ងឺចិត្តចំនួន៨០០០ ០០០៛(ប្រាំបីលានរៀល)។

-សុំអោយតុលាការអនុវត្តបណ្តោះអាសន្នលើប្រាក់ដើមចំនួន១១៦៥០(មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប)ដុល្លារអាមេរិច។

-សុំអោយចុងចំលើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

**៣-អង្គហេតុចាំបាច់សំរាប់ការបញ្ជាក់ទាមទារ**

ក-ដើមចោទ **ដ** ថ្លែងការណ៍ថា

កាលពី ឆ្នាំ២០១៤ ចុងចំលើយខាងលើបានមកខ្ចីចងការប្រាក់ពីនាងខ្ញុំចំនួន១៣៦៥០ (មួយម៉ឺនបីពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិច ហើយសន្យាអោយការប្រាក់៣%ក្នុង១ខែៗលុះតាំងពីនាងខ្ញុំអោយខ្ចីមកចុងចំលើយគាត់មិនបានអោយប្រាក់ដើមមកខ្ញុំមួយចំនួន២០០០(ពីរពាន់)ដុល្លារអាមេ

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ។

រិច ដោយនៅសល់ប្រាក់ដើម១១៦៥០(មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិច បន្ទាប់ពីនោះមកឈ្មោះនេះពុំបានបង់អោយទៀតទេ ទោះបីជាបានដាស់តឿនយ៉ាងណាក៏ដោយក៏គាត់មិនអោយដែរ ហើយបោះពាក្យថាមិនសង ដូច្នេះហើយនាងខ្ញុំសុំប្តឹងទាមទារដូចនៅក្នុងកម្មវត្ថុខាងលើ ។

<u>ឯកសារសំរាប់ត្រៀមភ្ជាប់ជាមួយមាន</u>

-កំណត់ហេតុចុះថ្ងៃទី២៣ខែជេស្ឋ ឆ្នាំ២០១៧។

ខ-ចុងចំលើយ ច ថ្លែងការណ៍ថា ខ្ញុំកន្លងមកធ្លាប់បានខ្ចីចងការប្រាក់ពីឈ្មោះ ផ ចំនួន១៣៦៥០ (មួយម៉ឺនបីពាន់ប្រាំមួយរយហាសិប)ដុល្លារអាមេរិច ហើយនៅឆ្នាំ២០១៧ ខ្ញុំសងបាន២០០០ (ពីរពាន់)ដុល្លារអាមេរិច និងពេលបន្ទាប់បានសងចំនួន១០០០(មួយពាន់)ដុល្លារអាមេរិច ហើយមុនឆ្នាំ២០១២ ខ្ញុំបានសង១០០០(មួយពាន់)ដុល្លារអាមេរិចសរុបទៅសងបាន៤០០០(បួនពាន់)ដុល្លារ និងមានលុយអ្នកផ្សេងខ្ចីដោយខ្ញុំជាអ្នកធានាមានចំនួន១៩៥០(មួយពាន់ប្រាំបួនរយហាសិប)ដុល្លារអាមេរិច

នៅពេលនេះខ្ញុំទទួលស្គាល់នៅជំពាក់លុយគាត់ចំនួន៧៧៥០(ប្រាំពីរពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិច ។ចំនួនទឹកប្រាក់ខាងលើខ្ញុំមិនមានលទ្ធភាពសងទេ តែទទួលស្គាល់ជំពាក់មែន។

ខ្ញុំមិនមានឯកសារណាច្បាស់ថា បានសងទៅដើមចោទទេ ពីព្រោះរាល់ការសងហុចផ្ទាល់ដៃ២ដង តាមវីង២ដង មិនមានលិខិតនៅសល់ទេ។

-ដើមចោទ ផ ថ្លែងការណ៍តបថា ខ្ញុំធ្លាប់ទទួលបានប្រាក់ពីចុងចំលើយបានតែ២០០០(ពីរពាន់ដុល្លារ)ក្រោយពីការខ្ចី ដូច្នេះនៅសល់ប្រាក់ដើម១១៦៥០(មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិច ចំណែកការដែលចុងចំលើយថានៅជំពាក់ចំនួន៧៧៥០ (ប្រាំពីរពាន់ប្រាំពីររយហាសិប)ដុល្លារអាមេរិចនោះខ្ញុំមិនទទួលយកទេ នៅតែទាមទារដូចពាក្យបណ្តឹង។

ចំពោះឯកសារកិច្ចសន្យាខ្ញុំមិនមានទេ តែមានកំណត់ហេតុដោះស្រាយនៅមុខមេឃុំចុះថ្ងៃទី២៣ខែ០៧ឆ្នាំ២០១៨។

-ចុងចំលើយ ច ថ្លែងការណ៍ថា ខ្ញុំនៅជំពាក់៧៧៥០ (ប្រាំពីរពាន់ប្រាំពីររយហាសិប)ដុល្លារអាមេរិច លើសពីនេះខ្ញុំមិនទទួលស្គាល់ទេ។

**៤-តុលាការកំណត់ចំណុចវិវាទ**

រឿងនេះដើមចោទបានប្តឹងទាមទារចំនួនប្រាក់ដើម១១៦៥០(មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប)ដុល្លារអាមេរិច តែចុងចំលើយថានៅជំពាក់ចំនួន៧៧៥០(ប្រាំពីរពាន់ប្រាំពីររយហាសិប)ដុល្លារអាមេរិច។

## ៥-សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ឃើញថា៖

-ដើមចោទ និង ចុងចំលើយ ពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគមានទឹកប្រាក់ចំនួន

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ។

១១៦៥០(មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិច ដោយយោងកំណត់ហេតុចុះថ្ងៃទី២៣ខែ ជេស្ឋ ឆ្នាំ២០១៧ តែចុងចំលើយថានៅជំពាក់ចំនួន៧៧៥០(ប្រាំពីរពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិច ក្នុងការដោះសារនេះចុងចំលើយមិនមានភស្តុតាងណាដែលនាំអោយតុលាការជឿបានឡើយ។

-តាមកិច្ចសន្យាជំពាក់ប្រាក់ធ្វើឡើងរវាងដើមចោទ និង ចុងចំលើយ រួមទាំងការចូលរួមនីតិវិធីត្រៀមសំរាប់ការទាញហេតុ ក៏ដូចជាការទាញហេតុផលផ្ទាល់មាត់ ឃើញថា ចុងចំលើយបានមកបញ្ជាក់ថាពិតជាបានខ្ចីប្រាក់នោះមែន តែទឹកប្រាក់មិនមែនចំនួនដូចការប្តឹងសុំទេ ដោយខ្លួនទទួលស្គាល់នៅជំពាក់ចំនួន៧៧៥០(ប្រាំពីរពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិច ដូច្នេះតុលាការពិចារណាលើចំណុចវិវាទ ។

-ក្នុងនោះដើមចោទនៅទាមទារប្រាក់ដើម ការប្រាក់តាមច្បាប់ និង ជម្ងឺចិត្ត៥០០០ ០០០៛(ប្រាំបីលានរៀល) ដូច្នេះតុលាការគប្បីសម្រេចទៅតាមច្បាប់។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចំលើយ។

## ៦-សេចក្តីសំរេចបញ្ចប់

១-ឱ្យចុងចម្លើយ ប សងប្រាក់ទៅដើមចោទ ផ ដូចខាងក្រោម:

ក-សងប្រាក់ដើមចំនួន ១១៦៥០ (មួយម៉ឺនមួយពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិច។

ខ-ការប្រាក់១៨%ក្នុង១ឆ្នាំគិតពីថ្ងៃទី២៣ ខែ០៧ ឆ្នាំ២០១៧ (កិច្ចសន្យាចុះថ្ងៃទី២៣ ខែ០៧ ឆ្នាំ២០១៧) រហូតសងប្រាក់គ្រប់ចំនួន។

គ-ប្រាក់សោហ៊ុយ និងជម្ងឺចិត្តចំនួន១ ០០០ ០០០៛(មួយលានរៀល)។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចំលើយ។

៣-សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ចំពោះមុខគូភាគី និង ប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ។

៤-ទុកសិទ្ធិអោយគូភាគីប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី**
**ហត្ថលេខានិងត្រា-យ៉ុន ប៉ុម**

**ចៅក្រម**
**ហត្ថលេខានិងត្រា-សាយសម្ផស្សសេរី**

........................................................................................................

បានឃើញ

នៅថ្ងៃទី១០ខែកញ្ញា ឆ្នាំ២០១៩

**ចៅក្រម**

បានចំលងត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃអង្គារ១២កើតខែភទ្របទឆ្នាំកុរឯកស័កពស២៥៦៣
កំពង់ចាម,ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ។